**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

**ជូនចំពោះ**

**ឯកឧត្តម សួន វ៉ានី អនុរដ្ឋលេខាធិការ និងលោក សួន រស្មី ប្រធាននាយកដ្ឋាន សវនកម្មផ្ទៃក្នុង ព្រមទាំងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីសោកស្តាយរញ្ជួយក្រៃលែង ដោយបានទទួលដំណឹងថា ឧបាសក **សួន ឡេន** ដែលត្រូវជាឪពុកបង្កើត ឯកឧត្តម **សួន វ៉ានី** អនុរដ្ឋលេខាធិការ និង លោក **សួន រស្មី** ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង បានទទួលមរណភាព នៅថ្ងៃសៅរ៍ ៨កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១៣:៣៤នាទី រសៀល ក្នុងជន្មាយុ ៨៤ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្តនិងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយជាអនេកប្បការជាមួយឯកឧត្តម និងលោក ព្រមទាំងក្រុមញាតិគ្រួសារ ចំពោះការបាត់បង់ ឧបាសក **សួន ឡេន** ដែលជាស្វាមី ឪពុក និងជីតាជាទីគោរពស្រលាញ់របស់ខ្លួន។

ខ្ញុំសូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធ ឧបាសក **សួន ឡេន** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម និងលោក ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃសៅរ៍ ៨ កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

ព្រុំ-សុខា